# "អគ្គិសនីឆ្មើងខ្លាំង: ផលប៉ះពាល់នៃការអភិវឌ្ឍន៍ទំនប់ដ៏លឿននៅក្នុងប្រទេសឡាវ"

**ដោយអង្គការទន្លេអន្តរជាតិ (International Rivers) (ខែ កញ្ញា ឆ្នាំ ២008)**

## សេចក្តីសង្ខេបប្រតិបត្តិ

ប្រទេសឡាវដ៏តូចកំពុងឆ្លងកាត់ការផ្លាស់ប្តូរធំៗ។ នៅពេលដែលប្រទេសឡាវខិតខំប្រែក្លាយខ្លួនទៅជា "ធុងអាគុយរបស់តំបន់អាស៊ីអគ្នេយ៍" ឧស្សាហកម្មវារីអគ្គិសនីរបស់ប្រទេសឡាវកំពុងលូតលាស់ខ្លាំង។ កំណើនតម្រូវការអគ្គិសនីពីប្រទេសជិតខាង ពោលគឺប្រទេសថៃឡង់ដ៏និងវៀតណាម និង វិនិយោគិនថ្មីមកពីប្រទេសថៃឡង់ដ៏ ចិន រុស្ស៊ី វៀតណាម និង ម៉ាឡេស៊ី កំពុងនាំមុខការពង្រីកនេះ។ ទំនប់ធំៗចំនួនប្រាំមួយ ជាផ្លូវការកំពុងស្ថិតក្នុងការសាងសង់នៅក្នុងប្រទេសឡាវ ហើយយ៉ាងហោចណាស់ ទំនប់ធំៗចំនួន ១២ ទៀត កំពុងស្ថិតក្នុងដំណាក់កាលធ្វើផែនការជឿនលឿនទៅមុខ។ ប្រទេសឡាវក៏កំពុងស្នើឡើងផងដែរនូវទំនប់ចំនួនប្រាំមួយសម្រាប់ទន្លេមេគង្គ។

អគ្គិសនីភាគច្រើនដែលផលិតដោយគម្រោងវារីអគ្គិសនីទាំងនេះ នឹងត្រូវបាននាំចេញទៅកាន់ប្រទេសទាំងឡាយ ដូចជាប្រទេសថៃ និង វៀតណាម ក៏ដូចជាប្រទេសកម្ពុជា និង ចិនផងដែរ។ ប្រសិនបើកិច្ចសន្យាអំណោយផលត្រូវបានចរចារជាមួយអ្នកទិញវារីអគ្គិសនីរបស់ប្រទេសឡាវ រដ្ឋាភិបាលឡាវអាចទទួលបានប្រាក់ចំណូលច្រើននៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ខាងមុខនេះ។ ប៉ុន្តែ នៅក្នុងប្រទេសមួយដែលរដ្ឋាភិបាលមានសមត្ថភាពទាបក្នុងការឃ្លាំមើលផលប៉ះពាល់របស់គម្រោងសាងសង់ទំនប់ ដែលនៅក្នុងនោះសេរីភាពត្រូវបានគេរឹតត្បិត តម្លាភាពគឺទាប ហើយអំពើពុករលួយគឺខ្ពស់ "ជំនន់" នៃគម្រោងវារីអគ្គិសនីថ្មីប្រកបដោយហានិភ័យខ្ពស់នេះ នាំឱ្យមានការបារម្ភសំខាន់ៗ។ អ្នកភូមិឡាវរាប់សែននាក់ទំនងជានឹងបាត់បង់ដីធ្លី ផលនេសាទ និង ធនធានផ្សេងទៀត នៅពេលដែលទំនប់ធំៗទាំងនេះត្រូវបានសាងសង់ ហើយប្រទេសឡាវពុំមានប្រវត្តិល្អទេក្នុងការគ្រប់គ្រងផលប៉ះពាល់សង្គម និងបរិស្ថាននៃទំនប់ធំៗ។

គម្រោងវារីអគ្គិសនីធំៗមួយចំនួនតូចដែលកំពុងដំណើរការនៅពេលនេះ ដូចជា ទំនប់ ហួយហូ (Houay Ho) និង ធឿនហ៊ីនប៊ុន (Theun-Hinboun) បានបង្កើនភាពក្រីក្រចំពោះប្រជាជនឡាវរាប់ម៉ឺននាក់។ អ្នកភូមិដែលត្រូវតាំងលំនៅឋានថ្មីមិនបានទទួលការស្តារប្រាក់ចំណូលរបស់ខ្លួនឱ្យបានដល់កម្រិតមុនមានគម្រោងទេ។ អ្នកភូមិខ្លះទៀតបានបាត់បង់ផលនេសាទដ៏សំខាន់ ដីស្រែ និង ចម្ការតាមមាត់ទន្លេ ប៉ុន្តែនៅមិនទាន់បានទទួលសំណងឬការសងជំនួសឱ្យបានគ្រប់គ្រាន់ឡើយ។

ទំនប់ធំបំផុតរបស់ប្រទេសឡាវ ពោលគឺ ទំនប់ណាមធឿន ២ កំពុងឈានចូលដល់ចុងបញ្ចប់នៃដំណាក់កាលសាងសង់ហើយ។ គម្រោងនេះមានបំណងជួយលើកកំពស់ស្តង់ដារបរិស្ថាននិងសង្គមដែលត្រូវអនុវត្តនៅក្នុងទូទាំងវិស័យវារីអគ្គិសនីឡាវ។ ប៉ុន្តែ ទំនប់ណាមធឿន ២ ខ្លួនឯង បានជួបប្រទះបញ្ហាតាំងលំនៅឋានថ្មី និង បញ្ហាសំណង ហើយកម្មវិធីទំនប់ដើម្បីដោះស្រាយផលប៉ះពាល់លើអ្នកភូមិដែលរស់នៅខាងក្រោមខ្សែទឹកមានគុណវិបត្តិច្រើន។ លើសពីនេះទៀត ជាក់ស្តែងគម្រោងសាងសង់ទំនប់ថ្មីដែលត្រូវបានអនុម័តតាំងពីមានទំនប់ណាមធឿន ២ បង្ហាញការដើរថយក្រោយនៅក្នុងការអនុវត្តន៍ខាងបរិស្ថាននិងសង្គម។ ទំនប់ណាមធឿន ២ មិនហាក់បីដូចជាកំពុងដឹកនាំការកែលម្អនៅក្នុងការរៀបចំ និងការគ្រប់គ្រងគម្រោងសាងសង់ទំនប់ឡាវ ដើម្បីដោះស្រាយផលប៉ះពាល់ លើសហគមន៍និងបរិស្ថានឡើយ។

ទោះបីជាច្បាប់ បទប្បញ្ញត្តិ និង គោលនយោបាយឡាវស្តីពីបរិស្ថាននិងសង្គម មានលក្ខណៈល្អលើក្រដាសក្តី ក៏ក្រុមហ៊ុនទាំងឡាយដែលសាងសង់ទំនប់នៅក្នុងប្រទេសឡាវមិនគោរពតាមវិធានទាំងនេះទេ។ រដ្ឋាភិបាលឡាវក៏ហាក់បីដូចជាមិនបង្ខំអនុវត្តច្បាប់និងគោលនយោបាយនានាដែលខ្លួនបានអនុម័តផងទេ។ ករណីសិក្សាចំនួន ១១ លើគម្រោងសាងសង់ទំនប់ដែលបានដាក់បញ្ចូលក្នុងរបាយការណ៍នេះ ប្រាប់រឿងគួរឱ្យបារម្ភអំពីការធ្វើផែនការមិនបានល្អ សំណងនិងវិធានការសម្រាលផលប៉ះពាល់មិនគ្រប់គ្រាន់ និង ការមិនគោរពតាមសន្យាចំពោះអ្នកភូមិដែលរងផលប៉ះពាល់ (សូមមើលតារាងនៅទំព័រ ៧-៩)។

ក្រុមហ៊ុនអភិវឌ្ឍទំនប់ ក្រុមហ៊ុនពិគ្រោះការងារ និង ក្រុមហ៊ុនសំណង់ កំពុងទទួលផលប្រយោជន៍ពីកង្វះធនធាន សមត្ថភាព និង អំណាចរបស់ទីភ្នាក់ងារធនធានទឹកនិងបរិស្ថានឡាវ (WREA)។ ទីភ្នាក់ងារធនធានទឹកនិងបរិស្ថានឡាវតាមពិតត្រូវធានាឱ្យបានថា ទំនប់ទាំងឡាយដែលសាងសង់នៅក្នុងប្រទេសឡាវត្រូវគោរពតាមច្បាប់និងគោលនយោបាយរបស់ប្រទេសស្តីពីបរិស្ថាននិងសង្គម។ ជារឿយៗ ទីភ្នាក់ងារធនធានទឹកនិងបរិស្ថានឡាវមិនបានយល់ព្រមលើផែនការសង្គមកិច្ចនិងបរិស្ថានសម្រាប់ទំនប់ទាំងនេះឡើយ មុនពេលការសាងសង់ចាប់ផ្តើម ហើយក្រុមហ៊ុនសាងសង់មិនត្រូវបានតម្រូវឱ្យផ្តល់មូលនិធិគ្រប់គ្រាន់ ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមានរបស់គម្រោងពួកគេលើអ្នកភូមិឡាវឡើយ។ ដោយសារទីភ្នាក់ងារធនធានទឹកនិងបរិស្ថានឡាវមិនមានមូលនិធិឬបុគ្គលិកដើម្បីឃ្លាំមើលទំនប់នៅក្នុងដំណាក់កាលសាងសង់ ឬដំណាក់កាលប្រតិបត្តិការ ក្រុមហ៊ុនទំនប់ជាច្រើនអាចកាត់បន្ថយចំណាយរបស់ខ្លួនដោយរំលោភបទប្បញ្ញត្តិឡាវ និង ការសន្យាដែលខ្លួនបានធ្វើចំពោះសហគមន៍រងផលប៉ះពាល់។ ជាចុងក្រោយ ដោយសារទីភ្នាក់ងារធនធានទឹកនិងបរិស្ថានឡាវមិនមានអំណាចបដិសេធគម្រោងទំនប់ដែលផ្តល់ទុក្ខទោសច្រើនបំផុតមួយចំនួន នៅតែត្រូវបានសាងសង់។

លើសពីនេះទៀត ពុំមាននីតិវិធីធ្វើផែនការយុទ្ធសាស្ត្រពិតប្រាកដ ឬ អភិក្រមគ្រប់គ្រងទូទាំងអាងទន្លេ ដែលផ្តល់ព័ត៌មានដល់របៀបដែលរដ្ឋាភិបាលឡាវជ្រើសរើសយក និង អនុម័តគម្រោងសាងសង់ទំនប់ឡើយ។ ថ្វីបើការសិក្សាត្រូវបានធ្វើនៅក្នុងបណ្តាឆ្នាំថ្មីៗនេះដើម្បីជួយកំណត់លំដាប់អាទិភាពគម្រោងនានា ទាក់ទិននឹងចំណាយ អត្ថប្រយោជន៍ និង ផលប៉ះពាល់ខាងបរិស្ថាននិងសង្គមក្តី ក៏អនុសាសន៍ទាំងឡាយនៃការសិក្សាទាំងនេះមិនត្រូវបានគេអនុវត្តតាមឡើយ។ វាហាក់បីដូចជាក្រុមហ៊ុនណាក៏ដោយដែលចង់សាងសង់ទំនប់នៅក្នុងប្រទេសឡាវ សុទ្ធតែត្រូវបានគេអនុញ្ញាតឱ្យសង់។ ការសាងសង់ទំនប់គ្មានសណ្តាប់ធ្នាប់នេះ បង្កើនចំណាយនិងផលប៉ះពាល់អវិជ្ជមាននៃការអភិវឌ្ឍន៍វារីអគ្គិសនីទាំងចំពោះរដ្ឋាភិបាលនិងប្រជាជនឡាវ។

ដោយសារទំនប់ធំៗស្ទើរតែទាំងអស់របស់ប្រទេសឡាវ នាំចេញអគ្គិសនីរបស់ខ្លួនឆ្លងកាត់ព្រំដែន អត្ថប្រយោជន៍ចម្បងរបស់ពួកគេ គឺប្រាក់ចំណូលដែលទទួលបានជាពន្ធ សួយសារ ភាគលាភ និង ការបង់ប្រាក់ផ្សេងទៀតជូនរដ្ឋាភិបាល។ ប្រទេសឡាវគឺជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតនៅក្នុងតំបន់ ហើយប្រាក់ចំណូលទាំងនេះគប្បីត្រូវបានប្រើប្រាស់ដើម្បីជួយកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។ ចំណុចនេះគឺជាការប្តេជ្ញាដែលបានធ្វើឡើងសម្រាប់ប្រាក់ចំណូលដែលនឹងទទួលបាននៅពេលដែលទំនប់ណាមធឿន ២ ចាប់ផ្តើមប្រតិបត្តិការនៅចុងឆ្នាំ ២០០៩។ ប៉ុន្តែ ប្រាក់តែឯកឯងនឹងមិនគ្រប់គ្រាន់ទេដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសឡាវ ប្រសិនបើគោលនយោបាយនិងគំនិតផ្តួចផ្តើមប្រកបដោយទុក្ខទោសមួយចំនួន នៅតែត្រូវបានបន្តគាំទ្រដោយរដ្ឋាភិបាលនិងម្ចាស់ជំនួយ។ គំនិតផ្តួចផ្តើមទាំងនេះ រួមមានការលុបបំបាត់កសិកម្មព្រៃដុត ការតាំងលំនៅឋានថ្មីក្នុងប្រទេស និង ការផ្តល់យ៉ាងលឿននូវសម្បទានវារីអគ្គិសនី រ៉ែ និង ចម្ការ ដែលកំពុងធ្វើឱ្យខូចខាតដល់សន្តិសុខស្បៀងអាហារ និង ឱកាសរកប្រាក់ចំណូលរបស់ប្រជាជននៅជនបទ។

គេឃើញមានជម្រើសអភិវឌ្ឍន៍ និងជម្រើសកាត់បន្ថយភាពក្រីក្រផ្សេងទៀតសម្រាប់ប្រទេសឡាវ ដែលជម្រើសទាំងនោះមួយចំនួនកំពុងត្រូវបានសិក្សានិងអនុវត្តរួចហើយដោយស្ថាប័នរដ្ឋាភិបាលឡាវ ដោយសហការជាមួយម្ចាស់ជំនួយ និង អង្គការមិនមែនរដ្ឋាភិបាល។ អភិក្រមទាំងនេះនឹងលើកស្ទួយលទ្ធភាពរបស់កសិករនៅតាមតំបន់វាលទំនាបនិងខ្ពង់រាបក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ ការការពារធនធានធម្មជាតិរបស់ខ្លួន និង ជួយពួកគេក្នុងការឆ្លៀតយកផលប្រយោជន៍ពីកាលានុវត្តភាពរកប្រាក់ចំណូលថ្មី។ យុទ្ធសាស្ត្រពីក្រោមឡើងលើនានា ដូចជា ការអភិវឌ្ឍន៍ទីផ្សារសម្រាប់ផលិតផលកសិកម្មពិសេស និង ការធានាសិទ្ធិដីធ្លីសហគមន៍ គួបផ្សំជាមួយនឹងយុទ្ធសាស្ត្រពីលើចុះក្រោមនានាដើម្បីកែលម្អតម្លាភាពរដ្ឋាភិបាលនិងការប្រមូលប្រាក់ចំណូល និងសមត្ថភាពគ្រប់គ្រង ចាំបាច់ត្រូវកំណត់ជាអាទិភាព និង ពង្រីក។

ទោះបីជារដ្ឋាភិបាលឡាវបានប្រកាសថា វារីអគ្គិសនីគឺជាអាទិភាពជាតិមួយក្តី ក៏ប្រទេសឡាវនឹងទទួលបានអត្ថប្រយោជន៍រយៈពេលវែងតិចតួចប៉ុណ្ណោះពីគម្រោងទាំងនេះ ប្រសិនបើមិនមានការពិចារណាមធ្យ័តអំពីប្រការដែលថា តើទំនប់វារីអគ្គិសនីគប្បីត្រូវបានសាងសង់នៅពេលណា សាងសង់យ៉ាងដូចម្តេច និង ថាតើគេគប្បីសាងសង់ទំនប់ទាំងនេះឬទេ។ ការប្រញាប់ប្រញាល់បំពេញសេចក្តីត្រូវការអគ្គិសនីរបស់ប្រទេសជិតខាតខ្លួន ឬ គោលដៅស្វែងរកចំណេញរបស់វិនិយោគិន ទំនងជានឹងផ្តល់ឱ្យប្រទេសឡាវនូវទុក្ខទោសជាងចំណុចល្អ។ អភិក្រមជម្រើស ប្រយ័ត្នប្រយែងមុខជាអនុញ្ញាតឱ្យរដ្ឋាភិបាលអាចប្រើប្រាស់ប្រាក់ចំណូលពីទំនប់មួយចំនួនតូចខាងមុខនេះ ដើម្បីកែលម្អសមត្ថភាពនិយ័តកម្មរបស់ខ្លួន និង លទ្ធភាពរបស់ខ្លួនក្នុងការចរចារកិច្ចសន្យាអំណោយផលជាមួយអ្នកទិញអគ្គិសនី។ ទំនប់ធំៗទាំងឡាយដែលមិនគោរពតាមច្បាប់ បទប្បញ្ញត្តិ និង គោលនយោបាយឡាវ ឬ ដែលនឹងនាំមកនូវទុក្ខទោសខាងបរិស្ថាននិងសង្គមដែលមិនអាចត្រឡប់ក្រោយបាន មិនគប្បីត្រូវបានសាងសង់ឡើយ។

អនុសាសន៍រួមសម្រាប់វិស័យវារីអគ្គិសនីឡាវ រួមមាន:

- **វាយតម្លៃឱ្យបានកាន់តែប្រសើរឡើងលើជម្រើសអភិវឌ្ឍន៍សម្រាប់ប្រទេសឡាវ។** រដ្ឋាភិបាលឡាវ និង ម្ចាស់ជំនួយ គប្បីវាយតម្លៃឱ្យបានពេញលេញតាមរយៈកិច្ចដំណើរការដែលមានការចូលរួមដ៏ទូលាយលើការកាត់បន្ថយភាពក្រីក្រ និង ជម្រើសរកប្រាក់ចំណូលសម្រាប់ប្រទេសឡាវ និង វាយតម្លៃលើថ្លៃចំណាយនិងអត្ថប្រយោជន៍នៃជម្រើសទាំងនេះ។
- **ពន្យឺតកំណើននៃគម្រោងសាងសង់ទំនប់ថ្មី។** រដ្ឋាភិបាលឡាវគប្បីពន្យឺតល្បឿននៃគម្រោងវារីអគ្គិសនីថ្មី និង ពិចារណាផ្អាកការយល់ព្រមលើកិច្ចព្រមព្រៀងសម្បទានសម្រាប់ទំនប់ថ្មី រហូតដល់ពេលដែលការវាយតម្លៃដ៏ពេញលេញ និងការធ្វើផែនការទូទាំងអាងត្រូវបានប្រើដើម្បីកំណត់លំដាប់អាទិភាពនៃការអភិវឌ្ឍន៍វារីអគ្គិសនី។
- **កាត់បន្ថយថ្លៃចំណាយ/បង្កើនអត្ថប្រយោជន៍។** ម្ចាស់ជំនួយនិងរដ្ឋាភិបាលឡាវគប្បីសហការគ្នាដើម្បីបង្កើនសមត្ថភាព អំណាច និង ធនធានរបស់ទីភ្នាក់ងារធនធានទឹកនិងបរិស្ថាននៃប្រទេសឡាវ។ សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការចរចារកិច្ចព្រមព្រៀងអំណោយផលជាមួយក្រុមហ៊ុនទិញអគ្គិសនីគប្បីត្រូវបានពង្រឹងផងដែរ។
- **កែលម្អការវាយតម្លៃបរិស្ថាននិងសង្គម។** រដ្ឋាភិបាលឡាវនិងក្រុមហ៊ុនអភិវឌ្ឍនទំនប់ គប្បីធានាឱ្យបាននូវការផ្សព្វផ្សាយឱ្យបានទាន់ពេលវេលានូវការសិក្សាលទ្ធភាពអនុវត្តគម្រោង និង សេចក្តីព្រាងរបាយការណ៍វាយតម្លៃបរិស្ថាននិងសង្គមជាភាសាឡាវនិងភាសាអង់គ្លេស និង ផ្សព្វផ្សាយតាមវិធី

ច្រើន រួមទាំងអ៊ិនធើណែតផង។ ការពិគ្រោះយោបល់ពេញលេញគប្បីត្រូវបានអនុវត្តដើម្បីកំណត់ចន្លោះប្រហោងនិងចំណុចខ្សោយទាំងឡាយនៅក្នុងការសិក្សាទាំងនេះ។

- **ជួយគាំទ្រជីវភាពនៅជនបទ។** រដ្ឋាភិបាលឡាវគប្បីបដិសេធផែនការតាំងលំនៅឋានថ្មីណាដែលមិនមានដាក់បញ្ចូលឯកសារលម្អិតអំពីការមានដីផលិតកម្មកសិកម្ម និងធនធាននៅក្នុងសំណើទីកន្លែងនៃការតាំងលំនៅឋានថ្មី។ រដ្ឋាភិបាលមិនគប្បីអនុវត្តគម្រោងសាងសង់ទំនប់ណាមួយឡើយ លុះត្រាណាតែការវាយតម្លៃមានដាក់បញ្ចូលទិន្នន័យចំណុចផ្តើម និង ការវាយតម្លៃដ៏ពេញលេញមួយលើផលប៉ះពាល់ជលផលខាងលើខ្សែទឹកនិងខាងក្រោមខ្សែទឹក។ សំណងសម្រាប់ការបាត់បង់ជលផលចំពោះគ្រប់សហគមន៍រងផលប៉ះពាល់ទាំងអស់ គប្បីត្រូវបានផ្តល់នៅក្នុងអំឡុងពេលអាយុគម្រោងទាំងស្រុង។ ប្រាក់ធានាការអនុវត្តន៍ ឬ យន្តការចំណងស្របច្បាប់ផ្សេងទៀតដើម្បីធានាឱ្យបានថាក្រុមហ៊ុនអភិវឌ្ឍទំនប់ត្រូវផ្តល់មូលនិធិគ្រប់គ្រាន់ដើម្បីដោះស្រាយផលប៉ះពាល់នៃគម្រោងរបស់ខ្លួនគប្បីត្រូវបានកំណត់។
- **ចែករំលែកអត្ថប្រយោជន៍ដោយផ្ទាល់ជាមួយប្រជាជនរងផលប៉ះពាល់។** រដ្ឋាភិបាលឡាវគប្បីបង្កើតយន្តការច្បាស់លាស់អាចដំណើរការបានដើម្បីធានាថា សហគមន៍រងផលប៉ះពាល់ពីទំនប់ទទួលបាននូវចំណែកនៃប្រាក់ចំណូលពីគម្រោង ឬ អត្ថប្រយោជន៍ផ្សេងទៀតនៅក្នុងអំឡុងពេលអាយុគម្រោងទាំងមូល។ ការចែករំលែកអត្ថប្រយោជន៍ ត្រូវតែធ្វើបន្ថែមលើសំណងចំពោះការបាត់បង់របស់ប្រជាជន។
- **ការពារធនធានសំខាន់ៗ។** ផ្អែកលើតម្លៃខាងបរិស្ថាន សង្គម សេដ្ឋកិច្ច និង វប្បធម៌ជាច្រើនរបស់វា ទន្លេមួយចំនួន ដូចជាទន្លេមេគង្គជាដើម មិនគប្បីត្រូវបានទប់ទំនប់ឡើយ។